ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣

សាលាដំបូងខេត្តព្រៃវែង
៣៥៧
សាលក្រមព្រហ្មទណ្ឌលេខ: ៥៣/០៧ច
ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ:៣១០
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៨

**គាទនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តព្រៃវែង

នារសៀល ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ មានសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តព្រៃវែង និង មានការប្រកាសសាលក្រមនារសៀលថ្ងៃទី១៧ ខែកុម្ភ ឆ្នាំ២០២០។

ដោយមានសមាសភាព

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រៃវែង

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

បានជំនុំជម្រះលើបណ្តឹងទាស់របស់ឈ្មោះស្រ៊ុន [redacted] ហៅ [redacted] ស្រ៊ាង ដែលបានប្តឹងទាស់នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ប្រឆាំងនឹងសាលក្រមកំបាំងមុខលេខ២០៤/២៨ច ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

សាលក្រមនេះបានសម្រេចទាក់ទងនឹងជនជាប់ចោទដូចតទៅៈ

៣. ផ្តន្ទាទោសឈ្មោះ [redacted] ស្រៀង ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងជួសជុលម៉ូតូ កើតនៅភូមិ [redacted] ខេត្តព្រៃវែង និងមានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] យឹន (រ) ម្តាយឈ្មោះ [redacted] ន់ យ៉ា (រ) ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ចំនួន៤(បួន)ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤(បួន)លានរៀល ពីបទប្រើប្រាស់ឯកសារសាធារណៈក្លែង តាមមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨។

Scanned with CamScanner

៨. បញ្ឈប់អនុភាពនៃដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ[redacted] ស្រៀង លេខ១៥ដបច.ព្រ ៦/២០១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរខេត្តព្រៃវែង។

១០. ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ឃុំខ្លួន ជនជាប់ចោទឈ្មោះ[redacted] ហួយ ហៅអ៊ួយ ជនជាប់ចោទឈ្មោះ[redacted] ស្រៀង ជនជាប់ចោទឈ្មោះ[redacted]ភារម្យ ស្របតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១២. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ [redacted] សុង ហៅរ៉ុង មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ[redacted] សុង កំបាំងមុខជនជាប់ចោទ[redacted] ស្រៀង ជនជាប់ចោទ[redacted] ហួយ ហៅអ៊ួយ និងជនជាប់ចោទផាត់ ភារម្យ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ ឬប្តឹងទាស់ តាមកំណត់ច្បាប់។

**ឯអង្គហេតុនៃរឿងមានដូចតទៅ:**

កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ កម្លាំងការិយាល័យជំនាញប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តព្រៃវែង បានប្រើប្រាស់ភ្នាក់ងារឲ្យញុះញង់ទិញថ្នាំញៀនពីឈ្មោះ [redacted] សុង ភេទប្រុស អាយុ២៤ឆ្នាំ មានទីលំនៅដូចខាងលើ ដោយណាត់ជួបគ្នានៅចំនុចហាងម្លប់ពុទ្រា ស្ថិតក្នុងភូមិកណ្តាល ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ លុះដល់វេលាម៉ោង១៤និង១៥នាទី ឈ្មោះ[redacted] សុង បានជិះម៉ូតូទៅជាមួយឈ្មោះ[redacted] រ៉េត ភេទប្រុស អាយុ៥០ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិល្វើយ ឃុំព្រាល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។ ពេលទៅដល់ ក៏ត្រូវកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថខេត្តព្រៃវែង ឃាត់ខ្លួនឈ្មោះ[redacted] សុង និងឈ្មោះ[redacted] រ៉េត ឆែកឆេរឃើញម្សៅក្រាមពណ៌សថ្លា ជាប្រភេទថ្នាំមេតំហ្វេតាមីន ចំនួន០១កញ្ចប់ មានទម្ងន់ 0,0៦ក្រាម ដែកមុខស្រួចសម្រាប់កាច់កម៉ូតូចំនួន០១ និងទូរសព្ទដៃម៉ាកណូគា ចុចពិលចំនួន០១គ្រឿង នៅលើឈ្មោះ[redacted] សុង។ ចំនែកឯឈ្មោះ[redacted] រ៉េត រកពុំឃើញមានអ្វីនោះទេ មានតែម៉ូតូ១គ្រឿង ម៉ាកC125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៨។

តាមចម្លើយរបស់ឈ្មោះ[redacted] សុង ម៉ូតូដែលឈ្មោះ[redacted] រ៉េត ជិះនោះជាម៉ូតូដែលខ្លួនបានលួចពីភូមិពូតាង ឃុំអូរជ្រៃ ស្រុកពេជ្រដា ខេត្តមណ្ឌលគីរី កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨ ជាមួយឈ្មោះ[redacted]ហួយ ហៅអ៊ួយ ហើយមានឈ្មោះ[redacted] ភារម្យ ជាអ្នករកផ្លាកលេខថ្មី មកពាក់ឲ្យម៉ូតូនេះ មុននឹងលក់ឲ្យឈ្មោះ[redacted] រ៉េត ក្នុងតម្លៃ៩៥០ដុល្លាអាមេរិក។

ក្នុងប្រតិបត្តិការនេះសមត្ថកិច្ចក៏បានរកឃើញឡានកាមរីបាឡែន គ្មានពន្ធ ពាក់ផ្លាកលេខក្លែងក្លាយ ភ្នំពេញ 1AB1168 ដែលឈ្មោះ[redacted] សុង ទិញពីឈ្មោះ [redacted] ស្រៀង ក្នុងតម្លៃ ៣៥០០ដុល្លាអាមេរិក។

# នាពេលសវនាការ

**ក្រោយពីបាន:**

- ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ[redacted] ស្រ៊ាង៖ ខ្ញុំមានឈ្មោះ[redacted] ស្រ៊ាង ហៅធី មានឪពុកឈ្មោះ[redacted] ស៊ិន់ ម្តាយឈ្មោះ [redacted]ផារី ប្រពន្ធឈ្មោះ[redacted] សាវុធ មានកូនម្នាក់។ កន្លងមកខ្ញុំធ្លាប់ជាប់ពន្ធនាគារនៅខេត្តរតនគីរី កាលពីឆ្នាំ២០១៦ ជាប់រយៈពេលមួយឆ្នាំ ពីបទក្លែងឯកសារ។ មូលហេតុដែលខ្ញុំប្តឹងទាស់នេះ ព្រោះថាខ្ញុំមិនបានធ្វើខុសទេ។ ខ្ញុំបានជូនដួង សុងទៅទិញឡានពីឈ្មោះភក្តិ តម្លៃ២ពាន់ដុល្លាជាង។ ឡាននោះគឺឡានកាមរី មានផ្លាកលេខស្រាប់ហើយ ឡាននោះមិនមែនជាឡានរបស់ខ្ញុំទេ។ ខ្ញុំគ្រាន់តែជួយជូនគេទៅប៉ុណ្ណោះ។ ខ្ញុំដឹងត្រឹមថាឡាននោះអត់ពន្ធ ត្រង់ផ្លាកលេខក្លែងក្លាយ ឬអត់ខ្ញុំអត់ដឹងទេ។
- ស្តាប់ចម្លើយសាក្សីឈ្មោះ[redacted] សុង៖ ពេលខ្ញុំទៅទិញឡាន ខ្ញុំទៅជាមួយឈ្មោះ[redacted] ស្រ៊ាង ហើយខ្ញុំជាអ្នកប្រគល់លុយឲ្យទៅឈ្មោះស្រ៊ាងនេះផ្ទាល់ដៃទៀតផង ហើយខ្ញុំក៏បើកឡានចេញមក ត្រង់ថាគេចែកលុយគ្នាយ៉ាងម៉េច ខ្ញុំមិនដឹងនោះទេ។ ឈ្មោះស្រ៊ាងនេះប្រាប់ខ្ញុំថាឡានអត់ពន្ធ គ្មានបញ្ហាអីទេ ជិះទៅ។ តម្លៃឡាន ៣ពាន់ តែខ្ញុំឲ្យតែ២៧០០ដុល្លា។ ពេលនោះខ្ញុំឃើញគ្នាគាត់មានគ្នា៣នាក់។ ពេលទិញឡាននោះពុំបានធ្វើលិខិតស្នាមអ្វីទេ។ គាត់មិនបានប្រាប់ខ្ញុំថាផ្លាកលេខនោះក្លែងក្លាយនោះទេ។
- ស្តាប់អំណានរបាយការណ៍លេខ០៥២/២០១៨ របក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០១៨។
- ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទរួចមកឃើញថា ពិតជាមានសកម្មភាពទិញលក់រថយន្ត ហើយដែលឈ្មោះ[redacted] សុង បានឆ្លើយចំពោះមុខនេះថាឈ្មោះ[redacted] ស្រ៊ាង នេះជូនទៅទិញ ប៉ុន្តែនៅពេលប្រគល់ប្រាក់ ដួង សុង បែរជាប្រគល់ប្រាក់ឲ្យទៅ[redacted] ស្រ៊ាងទៅវិញ។ ហើយកន្លងមក ឈ្មោះ[redacted] សុង នេះបានឆ្លើយប្រាប់សមត្ថកិច្ចយ៉ាងច្បាស់ថា រថយន្តនោះជារបស់ឈ្មោះ[redacted] ស្រ៊ាង ហើយដែលស្រ៊ាងនេះអះអាងទៀតថាជិះទៅមិនអីទេ ឡានរបស់គេទេ។មិនតែប៉ុណ្ណោះ ឈ្មោះស្រ៊ាងនេះបានប្រាប់អ្នកទិញទៀតថាឡានអត់ពន្ធទេ ហើយមកបដិសេធថាមិនដឹងផ្លាកលេខក្លែងក្លាយទៅវិញ។ ជាធម្មតាឡានអត់ពន្ធ មិនអាចមានផ្លាកលេខទេ បើមានគឺមានតែផ្លាកលេខក្លែងក្លាយ។ ដូច្នេះឃើញថាចម្លើយរបស់ជនជាប់ចោទឆ្លើយនៅពេលនេះ គឺដើម្បីដោះសារយករួចខ្លួន ប៉ុន្តែតំណាងអយ្យការនៅតែយល់ថា ជនជាប់ចោទបានប្រព្រឹត្តអំពើប្រើប្រាស់ឯកសារក្លែងដូចការចោទប្រកាន់ និងរក្សាការចោទប្រកាន់ទុកជាបានការដដែលទាំងស្រុង។



Scanned with CamScanner

-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាង ព្រមទាំងឯកសារនានានៅក្នុងសំណុំរឿងរួចមកឃើញថា កូនក្តីនាងខ្ញុំបានឆ្លើយបញ្ជាក់ហើយថាគាត់ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ ការខកខានមិនបានចូលរួមសវនាការនាពេលកន្លងមកគឺដោយសារតែគាត់មិនទទួលបានដំណឹងអំពីការកោះហៅ គាត់មិនមានចេតនាគេចវេសណាមួយឡើយ។ កូនក្តីខ្ញុំគ្រាន់តែជាអ្នកជូនឈ្មោះ [redacted] សុង ទៅទិញរថយន្តពីមិត្តភក្តិ ហើយគ្រាន់តែជាអ្នកទទួលលុយ និងប្រគល់រថយន្ត ព្រោះគាត់បានទទួលកម្រៃខ្លះពីការទិញលក់នេះ ទើបគាត់អះអាងថាយកទៅជិះទៅមិនអីទេ។ ហេតុនេះមិនមានធាតុផ្សំបទល្មើស ប្រើប្រាស់ឯកសារសាធារណៈក្លែង នោះទេ។ ស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីរួចផុតពីបទចោទប្រកាន់ និងដោះលែងឲ្យមានសេរីភាព ដើម្បីបានទៅរស់នៅជួបជុំគ្រួសារ មើលថែម្តាយចាស់ រកស៊ីចិញ្ចឹមគ្រួសារ និងមានឱកាសបានទៅព្យាបាលជំងឺ។

- ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ស្រ៊ាង សំណូមពរ៖ សុំឲ្យតុលាការសម្រេចដោះលែងឲ្យខ្ញុំបានចេញទៅព្យាបាលជម្ងឺនៅខាងក្រៅ។

**សំអាងហេតុ**

១. ជនជាប់ចោទបានទទួលដំណឹងអំពីសាលក្រមកំបាំងមុខ និងបានធ្វើការប្តឹងទាស់ស្របតាមនីតិវិធីច្បាប់។

២. ជនជាប់ចោទបានបដិសេធថាពុំមានជាប់ចោទពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារក្លែងដោយហេតុថាខ្លួនពុំបានដឹងថាផ្លាកលេខឡាននោះជាផ្លាកលេខក្លែងក្លាយ ប៉ុន្តែខ្លួនបានដឹងថាឡាននោះជាឡានអត់ពន្ធ។

៣. តុលាការយល់ស្របចំពោះសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការត្រង់ថា ជនជាប់ចោទបានដឹងយ៉ាងច្បាស់ថាឡាននោះជាឡានអត់មានពន្ធ នោះទេ ដូច្នេះផ្លាកលេខនោះប្រាកដជាផ្លាកលេខក្លែងក្លាយ ហើយជននេះនៅតែធ្វើការលក់ឲ្យទៅអ្នកដទៃទៀត។

៤. មួយវិញទៀត នៅពេលចាប់ខ្លួនជននេះ សមត្ថកិច្ចបានធ្វើការដកហូតផ្លាកលេខជាច្រើន ផងដែរ បើទោះបីជាផ្លាកលេខទាំងនោះមិនជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងសំណុំរឿងនេះក៏ដោយក៏វាអាចបង្ហាញថាជនជាប់ចោទរូបនេះ មានជាប់ពាក់ព័ន្ធនឹងរឿងផ្លាកលេខ(ក្លែងក្លាយ) ដូច្នេះការអះអាងថាខ្លួនមិនបានដឹងពីរឿងផ្លាកលេខសោះ ជាការអះអាងដែលមិនគួរឲ្យជឿ។

៥. តុលាការមិនយល់ស្របចំពោះសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទដូចមានសំអាងហេតុខាងលើ។

៦. តុលាការយល់ឃើញថាបណ្តឹងទាស់របស់ជនជាប់ចោទរូបនេះបានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ហើយតុលាការពិចារណាផងដែរថាជននេះបានចូលរួមសហការជាមួយសមត្ថកិច្ច ពុំបានបង្កការលំបាក ជននេះមានប្រពន្ធ និងកូនក្នុងបន្ទុក ដូច្នេះតុលាការសម្រេចបន្ធូរបន្ថយទោសពន្ធនាគារលើជននេះពី៤ឆ្នាំ ទៅជា៣ឆ្នាំវិញ។

- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>តុលាការសម្រេច</u>**

១. ទទួលបណ្តឹងទាស់របស់ជនជាប់ចោទ [redacted] ស្រៀង ទុកជាត្រឹមត្រូវតាមច្បាប់ ដែលសាលាដំបូងខេត្តព្រៃវែង អាចយកមកជំនុំជម្រះជាថ្មីម្តងទៀតតាមបញ្ញត្តិមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ផ្តន្ទាទោសឈ្មោះ [redacted] ស្រៀង ឬ [redacted] ស្រ៊ាង ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងជួសជុលម៉ូតូ កើតនៅភូមិបឹងជ័រ ឃុំព្រៃទទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និងមានទីលំនៅបច្ចុប្បន្ននៅភូមិស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] យីន (យ៉ាងស៊ិន) (រ) ម្តាយឈ្មោះ [redacted] យ៉ា (ពៅ ផារី) (រ) ប្រពន្ធឈ្មោះ [redacted] សាវុធ មានកូន១នាក់ ប្រវត្តិនៃការផ្តន្ទាទោស ធ្លាប់ជាប់ពន្ធនាគារនៅខេត្តរតនគិរីពីបទក្លែងឯកសារសាធារណៈ កាលពីឆ្នាំ២០១៦ (តាមការប្រាប់របស់សាមីខ្លួន)។

ដាក់ពន្ធនាគារកំណត់ចំនួន៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤.០០០.០០០(បួនលាន)រៀល ពីបទៈ ប្រើប្រាស់ឯកសារសាធារណៈក្លែង តាមមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

ប្រព្រឹត្តនៅភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨។

៣. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទស្រ៊ិន ស្រៀង និងមេធាវីការពារសិទ្ធិឲ្យ [redacted] ស្រៀង។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**ថ្ងៃទី....០៩....ខែ....០៦....ឆ្នាំ....២០២០**

**ក្រឡាបញ្ជី**

*សាលក្រមលេខ៥៣/០៧០ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០*

[redacted]